HIPAA: សេចក្តីជូនដំណឹង ពីការអនុវត្តន៍ភាពឯកជន

សេចក្តីជូនដំណឹងនេះ រៀបរាប់ទូវព័ត៌មានសុខភាពស្តីអំពីរូបអ្នក អាចនឹងត្រូវបានប្រើ និងត្រូវបានបើកសំដែងដោយរបៀបណា និងអំពីរបៀបដែលអ្នកមានលទ្ធភាពទទួលព័ត៌មាននេះ ។ សូមអានវាដោយយ៉ាងប្រិតប្រៀងបំផុត ។ ការផ្លាស់ប្តូរទៅលើសេចក្តីជូនដំណឹងនេះ នឹងមិនបានគោរពឡើយ ។

យើងនឹងសូមឲ្យអ្នកបញ្ជាក់ថាអ្នកបានទទួល សេចក្តីជូនដំណឹងពីការអនុវត្តន៍ភាពឯកជន របស់យើង ។

យើងយល់ថាព័ត៌មានស្តីអំពីរូបអ្នក និងសុខភាពរបស់អ្នកគឺជាបញ្ហាផ្ទាល់ខ្លួនបំផុត ហើយដោយសារហេតុនេះ យើងនឹងខ្មីឃ្មាតការពារភាពឯកជនរបស់អ្នក តាមច្បាប់បានដំរូវ ។ យើងនឹងប្រើ និងបើកសំដែងព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក តាមច្បាប់ជាធរមាន ដែលបានអនុញ្ញាតតែប៉ុណ្ណោះ ។

យើងបានប្តេជ្ញា ចំពោះការផ្គត់ផ្គង់ដ៏ល្អប្រសើរ នូវសេវាថែទាំសុខភាព-ទំនើប-ទាន់សម័យ ដោយការអនុវត្តន៍ថែទាំអ្នកជំងឺ ការរាប់រំ និងការស្រាវជ្រាវ ។ ដោយសារហេតុនេះ ដូចបានរៀបរាប់នៅខាងក្រោម ថាព័ត៌មានសុខភាពរបស់អ្នក នឹងត្រូវបានប្រើ ដើម្បីផ្តល់ការថែទាំអ្នក ហើយអាចនឹងបានប្រើសំរាប់ការរាប់រំអ្នកវិញ្ញាណីវៈថែទាំសុខភាព និងការស្រាវជ្រាវ ។ យើងហ្វឹកហ្វឺនបុគ្គលិក ព្រមទាំងពួកកំឡាំងការងាររបស់យើង ឲ្យយោគយល់អំពីភាពឯកជន ហើយក៏គោរពភាពសំងាត់នៃព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ។

ច្បាប់បានតម្រូវឲ្យយើងរក្សាភាពឯកជន នៃព័ត៌មានសុខភាពផ្ទាល់ខ្លួននៃអ្នកជំងឺរបស់យើង ហើយផ្តល់ឲ្យអ្នកនូវសេចក្តីជូនដំណឹង អំពីភារៈកិច្ចស្របច្បាប់របស់យើង ព្រមទាំងការអនុវត្តន៍ភាពឯកជន ដោយគោរពចំពោះព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ។ ច្បាប់បានដំរូវឲ្យយើងប្រព្រឹត្តតាមលក្ខខ័ណ្ឌនៃសេចក្តីជូនដំណឹង ពីការអនុវត្តន៍ភាពឯកជន ដរាបណាវានៅមានប្រសិទ្ធិភាព ។ យើងរក្សាសិទ្ធិផ្លាស់ប្តូរ សេចក្តីជូនដំណឹងពីការអនុវត្តន៍ភាពឯកជនតាមការចាំបាច់ ហើយធ្វើសេចក្តីជូនដំណឹងពីការអនុវត្តន៍ភាពឯកជនថ្មី ដែលមានប្រសិទ្ធិភាព សំរាប់ព័ត៌មានសុខភាពផ្ទាល់ខ្លួនទាំងអស់ ដែលយើងបានរក្សា ។ អ្នកអាចទទួលសំណៅនៃសេចក្តីជូនដំណឹងអ្នីមួយដែលបានកែ នៅឯមន្ទីរពេទ្យណាមួយ ឬនៅការិយាល័យរបស់គ្រូពេទ្យ ឬក៏អាចទទួលសំណៅនោះបាន ដោយសរសេរសំបុត្រស្នើទៅ UPHS Privacy Office, Office of Audit, Compliance and Privacy, 3819 Chestnut Street, Suite 214, Philadelphia PA 19104 ។

លក្ខខ័ណ្ឌនៃសេចក្តីជូនដំណឹងពីការអនុវត្តន៍ភាពឯកជននេះ អនុវត្តទៅលើអង្គភាព នៅខាងក្រោម ដែលជាម្ចាស់ ហើយបានប្រតិបត្តិដោយ និង/ឬ ជាសម្ព័ន្ធជាមួយ Trustees of the University of Pennsylvania (ក្រុមប្រឹក្សា វិចារណសភាសាលឡាល័យ Pennsylvania) : ជា University of Pennsylvania Health System ហើយនិងសាខា ព្រមទាំងសម្ព័ន្ធរបស់ខ្លួន ដោយរួមមានទូវ ប៉ុន្តែមិនកំរិតចំពោះ University of Pennsylvania Hospital (មន្ទីរពេទ្យនៃសាកលវិទ្យាល័យ Pennsylvania), មន្ទីរពេទ្យ Pennsylvania, មណ្ឌលពេទ្យ Penn Presbyterian, Clinical Practices នៃសាកលវិទ្យាល័យ Pennsylvania (CPUP), Clinical Care Associates (CCA), Clinical Health Care Associates of New Jersey, P.C. (CHCA), មណ្ឌលវះកាត់នៃមន្ទីរពេទ្យ Pennsylvania, Penn Medicine នៅ Radnor, មណ្ឌល Penn សំរាប់ការ ស្តារលទ្ធភាព និងការថែទាំ, Penn Home Infusion Therapy, Wissahickon Hospice, Penn Care at Home, មណ្ឌល Ruth និង Raymond Perelman for Advanced Medicine, Presbyterian Anesthesiology Foundation, Presbyterian Multi-Specialty Group Practice Foundation, University of Pennsylvania School of Medicine, Good Shepherd Penn Partners, Good Shepherd Penn Partners Specialty Hospital នៅ Rittenhouse, Good Shepherd Penn Partners Penn Therapy and Fitness ព្រមទាំង វេជ្ជបណ្ឌិត, អ្នកវិជ្ជាជីវៈមានអាជ្ញាប័ណ្ណ, បុគ្គលិក, អ្នកស្ម័គ្រចិត្ត, អ្នកហ្វឹកហ្វឺនដៃល មើល និងដែលព្យាបាលអ្នកជំងឺ នៅតាមទីកន្លែងទាំងនេះឡើយ ។ សេចក្តីជូនដំណឹងពីការអនុវត្តន៍ភាពឯកជននេះ មិនពាក់ព័ន្ធទេ នៅពេលវេជ្ជបណ្ឌិតដែលមិនមែនជា-CPUP, មិនមែនជា-CCA, ឬមិនមែនជា-CHCA ដែលមកមើលនៅក្នុងការិយាល័យពេទ្យឯកជនរបស់គេ ។

ការប្រើ និងការបើកសំដែង ព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក

ប្រភេទនៅខាងក្រោម ផ្តល់សេចក្តីក្បោះក្បាយនៃរបៀបជាច្រើន ដែលយើងអាចនឹងប្រើ ឬបើកសំដែងនូវព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ។ សំរាប់ប្រភេទនិមួយៗ នៃការប្រើ ឬការបើកសំដែង យើងនឹងផ្តល់ជូនអ្នកជាឧទាហរណ៍ពន្យល់ ។ អ្នកគួរតែត្រូវកត់សំគាល់ថា មិនមែនរាល់ការប្រើ ឬការបើកសំដែងទាំងអស់ នឹងបានចុះរាយទេ រីឯរបៀបនិមួយៗដែលបានអនុញ្ញាតឲ្យយើងប្រើ ឬបើកសំដែងព័ត៌មាន នឹងធ្លាក់ទៅក្នុងប្រភេទណាមួយនៅខាងក្រោម ។

ការអនុញ្ញាតរបស់អ្នក ។ លើកលែងតែបានគូសបញ្ជាក់នៅខាងក្រោម ទើបយើងនឹងមិនប្រើ ឬបើកសំដែងព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក សំរាប់គោលបំណងអ្វីមួយឡើយ លុះត្រាតែអ្នកចុះហត្ថលេខាលើក្រដាសបំពេញអនុញ្ញាតឲ្យប្រើ ឬបើកសំដែង ។ ក្រដាសបំពេញនេះរៀបរាប់អំពីព័ត៌មានអ្វីខ្លះ ទីងត្រូវបានបើកសំដែងបើកសំដែងទៅអ្នកណា សំរាប់គោលបំណងអ្វី និងនៅពេលណា ។ អ្នកមានសិទ្ធិដកហូតការអនុញ្ញាតវិញបានដោយសរសេរសំបុត្រ លើកលែងតែចំពោះវិសាលភាពដែលយើងបានពឹង រាងលើការអនុញ្ញាតនោះរួចទៅហើយ ។

ការប្រើ និងការបើកសំដែង សំរាប់ការព្យាបាល ។ យើងនឹងប្រើ និងបើកសំដែងព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក តាមការចាំបាច់ សំរាប់ការព្យាបាលអ្នក ។ ឧទាហរណ៍ ដូចជាគ្រូពេទ្យ ពេទ្យ និងអ្នកវិជ្ជាជីវៈផ្សេងទៀត ដែលចូលប្រឡូកក្នុងការថែទាំអ្នក នឹងប្រើព័ត៌មាន នៅក្នុងកំណត់ត្រាសុខភាពរបស់អ្នក ដើម្បីគ្រោងការព្យាបាលអ្នក ដែលអាចនឹងរួមមានទូវ វិធីវះកាត់ ថ្នាំពេទ្យ ការពិនិត្យសាកល្បងជាដើម ។ យើងក៏អាចនឹងបើកសំដែងព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ទៅវិជ្ជាស្ថាន និងបុគ្គលនៅខាងក្រៅ University of Pennsylvania Health System និង University of Pennsylvania School of Medicine ដែលព្យាបាលអ្នក ឬនឹងផ្តល់ការព្យាបាលឲ្យអ្នក ផងដែរ ។

ការប្រើ និងការបើកសំដែង សំរាប់ការបង់ប្រាក់ ។ យើងនឹងប្រើ និងបើកសំដែងព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក តាមការជាចាំបាច់សំរាប់គោលបំណងការបង់ប្រាក់ ។ សំរាប់ឧទាហរណ៍ យើងអាចនឹងបញ្ជូនបន្តនូវព័ត៌មាន ស្តីពីទំរង់ការពេទ្យ និងការព្យាបាលរបស់អ្នក ទៅឲ្យក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក ដើម្បីរៀបចំការបង់ប្រាក់សំរាប់ថ្លៃសេវា ដែលបានផ្តល់ឲ្យអ្នក ឬយើងអាចនឹងប្រើព័ត៌មានរបស់អ្នក ដើម្បីរៀបចំចេញវិក្កយបត្រផ្ញើទៅអ្នក ឬទៅមនុស្សដែលទទួលខុសត្រូវ សំរាប់ការបង់ប្រាក់ឲ្យអ្នក ។

ការប្រើ និងការបើកសំដែង សំរាប់ដំណើរការថែទាំសុខភាព ។ យើងនឹងប្រើ និងបើកសំដែងព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក តាមការចាំបាច់ និងតាមច្បាប់បានអនុញ្ញាត សំរាប់ដំណើរការថែទាំសុខភាព ។ នេះគឺជាការចាំបាច់ ដើម្បីចាត់ចែង University of Pennsylvania Health System និង University of Pennsylvania School of Medicine ហើយនិងដើម្បីឲ្យក្រុមគ្រូ ថាអ្នកជំងឺរបស់យើងទទួលការថែទាំប្រកបដោយគុណភាពខ្ពស់ ហើយថាអ្នកវិជ្ជាជីវៈថែទាំសុខភាពរបស់យើងទទួលការហ្វឹកហ្វឺនដ៏ខ្ពស់ ។ ឧទាហរណ៍ យើងអាចនឹងប្រើព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ដើម្បីធ្វើការប្រមាណាមើលនូវការព្យាបាល និងសេវាថាំងឲ្យាយដែលយើងផ្តល់ ឬដើម្បីពិនិត្យមើលឡើងវិញនូវកិច្ចការដែលបុគ្គលិករបស់យើងបំពេញ ។ ហើយព័ត៌មានសុខភាពរបស់អ្នក ក៏អាចនឹងបានបើកសំដែងទៅគ្រូពេទ្យ ពេទ្យ ឬអ្នកបច្ចេកទេស និស្សិតពេទ្យ វេជ្ជបណ្ឌិតហ្វឹកហ្វឺន បុគ្គលិក និងអ្នកផ្សេងទៀត សំរាប់គោលបំណងការរាប់រំ និងការហ្វឹកហ្វឺនដែរ ។

បញ្ជីឈ្មោះក្នុងមន្ទីររបស់យើង ។ យើងប្រើព័ត៌មាន ដើម្បីរក្សាបញ្ជីឈ្មោះ ដែលកត់ឈ្មោះ លេខបន្ទប់ និងលក្ខណៈទូទៅរបស់អ្នក ហើយបើសិនជាអ្នកក្រាថ្នំ ក៏កត់អំពីការកាន់សាសនារបស់អ្នក ។ លុះត្រាតែ អ្នកជ្រើសរើសកុំឲ្យបញ្ចូលព័ត៌មានរបស់អ្នកនៅក្នុងបញ្ជីឈ្មោះនេះ ដែលព័ត៌មាននោះ ដោយមិនរាប់ពីការកាន់សាសនារបស់អ្នក នឹងបានបើកសំដែងទៅជនណាម្នាក់ដែលស្នើសុំ ឬសួរអកឈ្មោះរបស់អ្នក ។ ព័ត៌មាននេះ ដោយរួមមានទាំងការកាន់សាសនារបស់អ្នក ក៏អាចនឹងបានផ្តល់ទៅឲ្យសមាជិកនៃពួកអាចារ្យផងដែរ សូម្បីតែបើគេមិនសួរអកឈ្មោះ របស់អ្នកក៏ដោយ ។ សូមអ្នកដំរាបបុគ្គលិករបស់យើងឲ្យដឹង នៅពេលអ្នកចូលមក ឬនៅពេលចុះឈ្មោះ បើសិនអ្នកមិនចង់ឲ្យបញ្ចូលព័ត៌មានរបស់អ្នក នៅក្នុងបញ្ជីឈ្មោះនេះទេ ។

មនុស្សដែលចូលប្រឡូកក្នុងការថែទាំអ្នក ។ លុះត្រាណាតែអ្នកមិនសុខចិត្ត សីមយើងអាចនឹងបើកសំដែងទៅឲ្យសមាជិកគ្រួសារ មិត្តភក្តិជិតស្និទ្ធរបស់អ្នក ឬមនុស្សដទៃទៀតដែលស្គាល់អ្នក តាមការិនិច្ឆ័យនៃវិជ្ជាជីវៈរបស់យើង ហើយយើងប្រើព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ដើម្បីសំរបសំរួលការចូលប្រឡូករបស់ជននោះ ក្នុងការថែទាំអ្នក ឬក្នុងការបង់ប្រាក់ សំរាប់ការថែទាំនោះ ។ យើងអាចនឹងប្រើ ឬបើកសំដែងព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ដើម្បីជួយជំរាបជំរលដំណឹងទៅសមាជិកគ្រួសារ អ្នកតំណាងផ្ទាល់ខ្លួន ឬមនុស្សដ៏ដទៃទៀត ដែលទទួលខុសត្រូវសំរាប់ការថែទាំអ្នក អំពីទីកន្លែង និងលក្ខណៈ:ទូទៅរបស់អ្នក ។ នៅទីបញ្ចប់ យើងក៏អាចនឹងបើកសំដែងព័ត៌មានសុខភាពផ្ទាល់ខ្លួនខ្លះៗ ទៅឲ្យសាធារណជន ឬអង្គភាពឯកជនដែលបានអនុញ្ញាតឲ្យជួយរំលែកទុក្ខក្នុងពេលមានគ្រោះអន្តរាយ ដើម្បីឲ្យអង្គភាពនោះអាចរកសមាជិកគ្រួសារ ឬមនុស្សផ្សេងៗទៀត ដែលអាចនឹងបានចូលប្រឡូកក្នុងទិដ្ឋភាពខ្លះៗនៃការថែទាំអ្នក ។

ការអង្កាសវិភា ។ យើងអាចនឹងទាក់ទងអ្នក នៅពេលត្រូវការសំរបសំរួលជាមួយនឹងវេជ្ជបណ្ឌិតរបស់អ្នក ធ្វើអំណោយក្នុងការខំប្រឹងប្រែងអង្កាសប្រាក់ ក្នុងនាមរបស់យើង ។ លើសិនជាយើងទាក់ទងអ្នក សំរាប់គោលបំណងនៃការអង្កាសប្រាក់ អ្នកនឹងបានឲ្យឱកាស ដើម្បីជ្រើសរើសមិនទទួលការអំពាវនាវអ្វីមួយនៅពេលអនាគត ។

ការណាត់ពេលជួប និងសេវា ។ យើងអាចនឹងប្រើព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ដើម្បីរំលឹកអ្នកអំពីការណាត់ពេលជួប ឬការជួបពិនិត្យជាបន្តបន្ទាប់ទៀតរបស់អ្នក ។

ផលិតផលសុខភាព និងសេវា ។ ម្យ៉ាងម្តង យើងអាចនឹងប្រើព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ដើម្បីក្រាស្រ័យទាក់ទងជាមួយអ្នក អំពីការព្យាបាលផ្សំនឹងទៀត ព្រមទាំងអំពីអត្ថប្រយោជន៍ផ្សេងៗទៀត ជាប់ទាក់ទងខាងសុខភាព ព្រមទាំងអំពីសេវាដែលអាចនឹងមានប្រយោជន៍ដល់អ្នក ។

ការស្រាវជ្រាវ ។ យើងអាចនឹងប្រើ និងបើកសំដែងព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក តាមច្បាប់បានអនុញ្ញាត ឬបានដំរូវសំរាប់ការស្រាវជ្រាវ ដែលយោងទៅលើការអនុញ្ញាតជាក់លាក់របស់អ្នក និង/ឬ ការរវាំងមើលដោយគណៈពិនិត្យពិធីយវិជ្ជាស្ថាននៃសាកលវិទ្យាល័យ Pennsylvania (University of Pennsylvania Institutional Review Boards) ឬហៅកាត់ថា IRB ជាគណៈកម្មាធិការទទួលបន្ទុកខាងការពារសិទ្ធិភាពឯកជន និងសុវត្ថិភាពនៃបុគ្គលចូលរួមការស្រាវជ្រាវ ឬគណៈកម្មាធិការដែលស្រដៀង ។ នៅក្នុងករណីទាំង អស់ដែលការអនុញ្ញាតជាក់លាក់របស់អ្នក មិនទាន់បានទទួលនៅឡើយ នោះភាពឯកជនរបស់អ្នកនឹងបានការពារដោយសេចក្តីដំរូវនៃភាពសំងាត់ ដែលបានប្រមាណមើលដោយគណៈកម្មាធិការនោះ ។ ឧទាហរណ៍ IRB អាចនឹងបរិយាយច្បាប់ប្រើព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ទូវព័ត៌មានដែលសំគាល់អ្នកតាមតែបន្តិចបន្តួចតែប៉ុណ្ណោះ ដើម្បីរកលទ្ធផលនៃការស្រាវជ្រាវ ដើម្បីឲ្យដឹងក្រែងលោទំរង់ការណាមួយមានប្រសិទ្ធិភាព ។

សហការីជំនួញ ។ នៅក្នុងទិដ្ឋភាព និងសមាសភាគខ្លះនៃសេវារបស់យើង ដែលបានធ្វើតាមរយៈកុងត្រាជាមួយនឹងមនុស្ស ឬអង្គការខាងក្រៅ ដូចជាការជំរះបញ្ជីក្រៅ ការទទួលស្គាល់ជាផ្លូវការ សេវាខាងច្បាប់ ជាដើម ។ នៅពេលខ្លះ វាអាចនឹងជាការចាំបាច់សំរាប់យើង ដើម្បីផ្តល់ព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នកខ្លះ ទៅឲ្យមនុស្ស ឬអង្គការនៅខាងក្រៅទាំងនេះ ដែលជួយយើងក្នុងសកម្មភាពការបង់ប្រាក់/វិក្កយបត្ររបស់យើង និងដំណើរការថែទាំសុខភាព ។ នៅក្នុងករណីដូចគ្នោះ យើងដំរូវឲ្យសហការីជំនួញទាំងនេះ ការពារភាពឯកជននៃព័ត៌មានរបស់ អ្នកយ៉ាងសមរម្យ ។

ការប្រើ និងការបើកសំដែងផ្សេងៗទៀត ។ ច្បាប់បានអនុញ្ញាត និងបានដំរូវឲ្យយើងប្រើ និងបើកសំដែង នូវព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នកខ្លះ ដោយពុំបាច់មានសេចក្តីយល់ព្រម ឬការអនុញ្ញាតពីអ្នកឡើយ ។ ដោយគោរពចំពោះលក្ខខ័ណ្ឌដែលច្បាប់បានបញ្ជាក់ :

- យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក សំរាប់គោលបំណងអ្វីមួយ ដែលច្បាប់បានដំរូវ;
- យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក សំរាប់សកម្មភាពនៃសុខភាពសាធារណៈ ដូចបានដំរូវសំរាប់ការប៉ាងការណ៍ជំងឺ របួស ការកើត ការស្លាប់ និងបានដំរូវសំរាប់ការស៊ើបអង្កេតសុខភាពសាធារណៈ;
- យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ទៅឲ្យភ្នាក់ងារដ្ឋាភិបាលមួយចំនួន លើសិនជាយើងសង្ស័យអំពីការធ្វើទុក្ខទោស ឬការព្រួតលើមកនន្តើយដល់ក្មេង; យើងក៏អាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ទៅឲ្យភ្នាក់ងារដ្ឋាភិបាលផ្សេងៗដែរ លើសិនជាយើងជឿថាអ្នកជាជនរងគ្រោះនៃការធ្វើទុក្ខទោស ការព្រួតលើមកន្តើយ ឬរង់ពើហឹង្សាក្នុងគ្រួសារ;
- យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ទៅឲ្យអង្គភាពដែលបានដាក់បញ្ជាត្តិ ដោយនាយកដ្ឋានណោជនភាណ្ឌ និង ឱសថូបកណ៍ (FDA) លើសិនជាចាំបាច់ ដើម្បីរាយការណ៍នៃព្រឹត្តិការណ៍មិនល្អ ផលិតផលមិនល្អ ឬដើម្បីចូលរួមក្នុងផលិតផលដែល គេហៅឲ្យយកមកវិញ;
- យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ទៅឲ្យក្រុមហ៊ុនការងាររបស់អ្នក នៅពេលយើងបានផ្តល់ការថែទាំសុំខភាពឲ្យអ្នក តាមសំណូមពរមកពីក្រុមហ៊ុនការងាររបស់អ្នក សំរាប់គោលបំណងដែលជាប់ទាក់ទងនឹងសុខភាពអាជីវកម្ម និងសុវត្ថិភាពការងារ; នៅក្នុងករណីភាគច្រើន អ្នកនឹងទទួលសេចក្តីជូនដំណឹង ថាព័ត៌មាននោះបានបើកសំដែង ទៅឲ្យក្រុមហ៊ុនការងាររបស់អ្នក;
- បើច្បាប់បានតម្រូវ យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នកទៅឲ្យភ្នាក់ងារដ្ឋាភិបាលរាំងមើលការជំរះបញ្ជី ការស៊ើបអង្កេត ការត្រួតពិនិត្យ និងមុខងារជាប់ទាក់ទងនឹងការរាំងមើល;
- យើងអាចនឹងប្រើ ឬបើកសំដែង ព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ក្នុងកាលៈទេសៈ ជាអាសន្ន ដូចជាដើម្បីការពារភាពធ្ងន់ធ្ងរ និងការគំរាមកំហែង ដែលនឹងកើតឡើងចំពោះមនុស្សម្នា ឬសាធារណជន;
- យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក បើសិនជាតុលាការ ឬបទបញ្ជាតុលាការបានដំរូវឲ្យយើងធ្វោះបោរ ឬសំរុំស្នើការ បញ្ចេញហេតុការណ៍; នៅក្នុងករណីភាគច្រើន អ្នកនឹងទទួលសេចក្តីជូនដំណឹងអំពីការបញ្ចេញបែបនោះ;
- យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ទៅឲ្យភ្នាក់ងារនគរបាល ដើម្បីកត់សំគាល់ ឬរកជនសង្ស័យ រកជនរត់គេចវេះច្បាប់ ឬរកសាក្សី ឬក៏សំគាល់ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬក៏សំរាប់គោលបំណងនៃការប្រតិបត្តិតាមច្បាប់ផ្សេងៗទៀត ដែលបានអនុញ្ញាត;
- យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ទៅឲ្យមរណហេតុបណ្ឌិត ពេទ្យពិនិត្យបុព្វហេតុមរណៈ និង/ឬ នាយកទីដុតសាល;
- យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក បើសិនជាចាំបាច់ ដើម្បីរៀបចំការធ្វើអំណោយសរីរាង្គ ឬជាលិកា ពីអ្នក ឬការផ្សាំសរីរាង្គ សំរាប់អ្នក;
- យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក បើសិនអ្នកជាសមាជិកយោធា សំរាប់សកម្មភាពជាក់លាក់ ដែលបានចែងដោយអាជ្ញាធរបញ្ជាការយោធា ដូចបានដំរូវដោយកងកំឡាំងប្រជាប់អាវុធ; យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក បើសិនជាចាំបាច់ សំរាប់សន្តិសុខជាតិ ការស៊ើបការណ៍ ឬក៏សកម្មភាពសេវាការពារ; និង
- យើងអាចនឹងបញ្ចេញព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក បើសិនជាចាំបាច់ សំរាប់គោលបំណងជាប់ទាក់ទងនឹងអត្ថប្រយោជន៍ការសងគ្រាក់ផ្សកម្មករ ព្រោះមានគ្រោះថ្នាក់នៅការដ្ឋាន ។

ភាពសំងាត់នៃកំណត់ត្រារបស់អ្នកជំងឺ អំពីការរំលោភស្រា និងគ្រឿងញៀន ព័ត៌មានជាប់ទាក់ទងនឹងរោគហ៊ីវ និងកំណត់ត្រាសុខភាពអារម្មណ៍ ។ ភាពសំងាត់នៃកំណត់ត្រារបស់អ្នកជំងឺ អំពីការរំលោភស្រា និងគ្រឿងញៀន ព័ត៌មានជាប់ទាក់ទងនឹងរោគហ៊ីវ (HIV) និងកំណត់ត្រាសុខភាពអារម្មណ៍ ដែលយើងបានរក្សាទុក គឺត្រូវបានការពារយ៉ាងពិសេសដោយច្បាប់ និងបញ្ញត្តិរបស់រដ្ឋ និង/ឬ នៃរដ្ឋបាលសហព័ន្ធ ។ ជាទូទៅ យើងមិនអាចនឹងបើកសំដែងព័ត៌មានដូច្នោះបានឡើយ លុះត្រាណាតែអ្នកយល់ព្រមជាលាយលក្ខណ៍អក្សរ ហើយការបើកសំដែងត្រូវបានអនុញ្ញាតដោយបទបញ្ជាតុលាការ ឬក៏បានកំរិត និងបានជាក់បញ្ជាត្តិ នៅក្នុងកាលៈទេសៈផ្សេងៗទៀត ។

សិទ្ធិដែលអ្នកមាន

អ្នកអាចមើលព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នកបាន ។ តាមធម្មតា អ្នកមានសិទ្ធិមើល ត្រួតពិនិត្យ និង/ឬ ថតចំឡុង នូវព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ដែលយើងរក្សាទុកស្តីអំពីអ្នក ។ សំណើសុំមើល ត្រូវតែបានធ្វើជាលាយលក្ខណ៍អក្សរ ហើយបានចុះហត្ថលេខាដោយអ្នក ឬអ្នកតំណាងរបស់អ្នក លុះត្រាតែនៅពេលបច្ចុប្បន្ននេះអ្នក ជាអ្នកជំងឺមួយរូប នៅក្នុងមន្ទីរពេទ្យរបស់យើង ឬក្នុងពេលបានគ្រោងណាត់ជួបជាមួយអ្នកពិនិត្យព្យាបាល ។ យើងនឹងទារថ្លៃពីអ្នក សំរាប់ការថតចំឡុងតំណាត់ត្រាសុខភាពរបស់អ្នក តាមកំរិតថ្លៃឈ្នួលដែលបានស្ថាបនាដោយច្បាប់រដ្ឋជាធរមាន ។ អ្នកអាចទទួលក្រដាសបំពេញសំណើ ពីការិយាល័យគ្រូពេទ្យរបស់អ្នក ឬក្រសួងរក្សាកំណាត់ត្រាសុខភាព នៅមន្ទីរពេទ្យដែលអ្នកបានទៅព្យាបាល ។

ការកែប្រែព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ។ អ្នកមានសិទ្ធិស្នើសុំឲ្យ យើងកែប្រែ ឬកែដំរូវ នូវព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ដែលយើងបានរក្សាទុក ។ យើងមិនបានដំរូវឲ្យធ្វើការកែប្រែទៅតាមសំណើទាំងអស់ឡើយ ប៉ុន្តែនឹងពិចារណាដោយប្រិតប្រៀងចំពោះសំណើនិមួយៗ ។ ដើម្បីឲ្យយើងអាចពិចារណាកើត សំណើសុំកែប្រែទាំងអស់ត្រូវតែមានជាលាយលក្ខណ៍អក្សរ បានចុះហត្ថលេខាដោយអ្នក ឬអ្នកតំណាងរបស់អ្នក ហើយសំណើត្រូវតែផ្តែងអំពីមូលហេតុ សំរាប់ការកែប្រែ/កែដំរូវ ។ បើយើងបានធ្វើការកែប្រែ ឬកែដំរូវ ទៅតាមសំណូមពររបស់អ្នក យើងក៏អាចនឹងជំរាបទៅអ្នកផ្សេងៗទៀត ដែលធ្វើការជាមួយយើង ហើយដែលមានសំណៅនៃកំណត់ត្រាមិនបានកែ បើយើងជឿថាការជំរាបដំណឹងនោះជាការចាំបាច់ ។ សូមចំណាំថា សូម្បីតែបើយើងយល់ព្រមចំពោះសំណើរបស់អ្នកក្តី គង់តែយើងមិនអាចលុបចោលព័ត៌មានអ្វីៗដែលបានកត់ជាឯកសារនៅក្នុងកំណត់ត្រាសុខភាពរបស់អ្នក បានឡើយ ។ អ្នកអាចទទួលក្រដាសបំពេញសំណើសុំកែប្រែ ពីការិយាល័យគ្រូពេទ្យរបស់អ្នក ឬក្រសួងរក្សាកំណាត់ត្រាសុខភាពនៅមន្ទីរពេទ្យដែលអ្នកបានទៅព្យាបាល ។

បញ្ជីសំរាប់ការបើកសំដែង នូវព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ។ អ្នកមានសិទ្ធិទទួលបញ្ជីនៃការបើកសំដែងព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក មួយចំនួនដែលយើងបានធ្វើលើកលែងតែការបើកសំដែងបានធ្វើ សំរាប់គោលបំណងនៃការព្យាបាលការបង់ប្រាក់ និងដំណើរការថែទាំសុខភាព ឬសំរាប់ការលើកលែងផ្សេងខ្លះទៀត ។ បញ្ជីនេះនឹងមានបញ្ចូលតែការបើកសំដែងទាំងនោះប៉ុណ្ណោះ ដែលបានធ្វើក្នុងពេលប្រាំមួយឆ្នាំមុន មកដល់ថ្ងៃខែឆ្នាំដែលបញ្ជីនោះបានស្នើ ប៉ុន្តែនឹងពុំមានបញ្ចូលការបើកសំដែង ដែលបានធ្វើនៅមុនថ្ងៃទី 13 ខែមេសា ឆ្នាំ 2003 ឡើយ ។ សំណើត្រូវតែបានធ្វើជាលាយលក្ខណ៍អក្សរ និងបានចុះហត្ថលេខាដោយអ្នក ឬអ្នកតំណាងរបស់អ្នក ។ ក្រដាសបំពេញសំណើ គឺមាននៅការិយាល័យគ្រូ ពេទ្យរបស់អ្នក ឬនៅក្រសួងសេវាឆ្មាំវ៉ូ នៃមន្ទីរពេទ្យដែលអ្នកបានទៅព្យាបាល ។ បញ្ជីជាលើកដំបូង នៅក្នុងរយៈពេល 12 ខែណាមួយ គឺឥតគិតថ្លៃទេ; អ្នកនឹងបានទារថ្លៃឈ្នួល $20 សំរាប់សំណើសុំបញ្ជីក្នុងរយៈ ពេល 12 ខែ ជាលំដាប់បន្ទាប់មកទៀត ។

ការដាក់លក្ខខ័ណ្ឌ ទៅលើការប្រើនិងការបើកសំដែង នូវព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ។ អ្នកមានសិទ្ធិស្នើសុំការដាក់លក្ខខ័ណ្ឌ អំពីរបៀបខ្លះៗដែលយើងប្រើ និងបើកសំដែង នូវព័ត៌មានសុខភាពរបស់អ្នក សំរាប់ការព្យាបាល ការបង់ប្រាក់ ឬដំណើរការថែទាំសុខភាព ។ ឧទាហរណ៍ អ្នកអាចស្នើកុំឲ្យយើងថែកចាយព័ត៌មានសុខភាពផ្ទាល់ខ្លួនរបស់អ្នក ជាមួយនឹងសមាជិកគ្រួសារណាមួយ ។ អ្នកអាចទទួលក្រដាសបំពេញសំណើសុំការដាក់លក្ខខ័ណ្ឌ ពីការិយាល័យគ្រូពេទ្យរបស់អ្នក ឬក្រសួងសេវាឆ្មាំវ៉ូ នៃមន្ទីរពេទ្យដែលអ្នកបានទៅព្យាបាល ។ យើងមិនបានដំរូវឲ្យយល់ព្រម